# ឯកឧត្តម ចម ប្រសិទ្ធ និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្ញើសារលិខិតជូនពរ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ក្នុងឱកាសខួបកំណើតគម្រប់៧៣ឆ្នាំ ឈានចូល៧៤ឆ្នាំ




ភ្នំពេញ៖ ខ្ញុំបាទ ចម ប្រសិទ្ធ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមគោរពអនុញ្ញាតសម្តែងនូវមនោសញ្ចេតនារំភើបរីករាយក្រៃលែង និងសូមគោរពផ្ញើជូន សម្តេចវិបុលសេនាភក្តី នូវពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ ក្នុងឱកាសការប្រារព្ធខួបកំណើតគម្រប់ ៧៣ឆ្នាំ ឈានចូល ៧៤ឆ្នាំ នាថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងសូម សម្តេចវិបុលសេនាភក្តី ទទួលបាននូវសុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំព្រឹទ្ធសភាជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា
ឱ្យទទួលបាននូវសមិទ្ធិផលថ្មីៗ បន្ថែមទៀត។

នាឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមលំឱនកាយសម្តែងនូវការគោរពដ៏ស្មោះសរ និងខ្ពង់ខ្ពស់ ចំពោះ សម្តេចវិបុលសេនាភក្តី ក្នុងការខិតខំប្រឹងប្រែងប្រកបដោយការចិត្តទុកដាក់ លះបង់កម្លាំងកាយ និងប្រាជ្ញាស្មារតី ដើម្បីដឹកនាំស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូល

នៃព្រះរាជាណាចក្រកម្ពុជា សម្រេចបានសមិទ្ធិផល និងស្នាដៃត្រចះ ត្រចង់ជាច្រើន រួមចំណែកដល់ដំណើរការពង្រឹងនីតិរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍លិទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ទន្ទឹមនេះ សម្តេចវិបុលសេនាភក្តី ក៏បានចូលរួមចំណែកយ៉ាងធំធេងក្នុងបុព្វហេតុកសាង ស្តារ និងអភិវឌ្ឍមាតុភូមិ នាំមកនូវសន្តិភាព ឯកភាពជាតិ និងភាពសុខដុមជូនប្រជាពលរដ្ឋ និងសង្គមកម្ពុជាទាំងមូល។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះផងដែរ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម គ្រប់លំដាប់ថ្នាក់ សូមលើកហត្ថប្រណមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះមេត្តាប្រោសប្រទានពរជ័យ សិរីមង្គល បវរមហាប្រសើរ ជូនចំពោះសម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី និងក្រុមគ្រួសារ ជាទីស្រលាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរដ៏ប្រពៃថ្លៃថ្លាទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

សូម សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សារលិខិតជូនពរ**

**សូមគោរពជូនពរ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**
**ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមគោរពអនុញ្ញាតសម្តែងនូវមនោសញ្ចេតនារំភើបរីករាយក្រៃលែង និងសូមគោរពផ្ញើជូន **សម្តេចវិបុលសេនាភក្តី** នូវពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ ក្នុងឱកាសការប្រារព្ធខួបកំណើតគម្រប់ ៧៣ឆ្នាំ ឈានចូល ៧៤ឆ្នាំ នាថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងសូម **សម្តេចវិបុលសេនាភក្តី** ទទួលបាននូវសុខភាពល្អបរិបូណ៌ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំព្រឹទ្ធសភាជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបាននូវសមិទ្ធិផលថ្មីៗ បន្ថែមទៀត។

នាឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមលំឱនកាយសម្តែងនូវការគោរពដ៏ស្មោះសរ និងខ្ពង់ខ្ពស់ ចំពោះ **សម្តេចវិបុលសេនាភក្តី** ក្នុងការខិតខំប្រឹងប្រែងប្រកបដោយការចិត្តទុកដាក់ លះបង់កម្លាំងកាយ និងប្រាជ្ញាស្មារតី ដើម្បីដឹកនាំស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបានសមិទ្ធិផល និងស្នាដៃត្រចះត្រចង់ជាច្រើន រួមចំណែកដល់ដំណើរការពង្រឹងនីតិរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍លិទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ទន្ទឹមនេះ **សម្តេចវិបុលសេនាភក្តី** ក៏បានចូលរួមចំណែកយ៉ាងធំធេងក្នុងបុព្វហេតុកសាង ស្តារ និងអភិវឌ្ឍមាតុភូមិ នាំមកនូវសន្តិភាព ឯកភាពជាតិ និងភាពសុខដុមជូនប្រជាពលរដ្ឋ និងសង្គមកម្ពុជាទាំងមូល។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះផងដែរ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម គ្រប់លំដាប់ថ្នាក់ សូមលើកហត្ថប្រណមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះមេត្តាប្រោសប្រទានពរជ័យ សិរីមង្គល បវរមហាប្រសើរ ជូនចំពោះ **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា និង លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី និងក្រុមគ្រួសារ ជាទីស្រលាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរដ៏ប្រពៃថ្លៃថ្លាទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

ថ្ងៃច័ន្ទ ០៥រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ទេសរដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**